# ការបង្ហាញទេពទុគ៌ានៅប្រាសាទសំបូរព្រៃគុក

ទុគ៌ា គឺជាទេពស្រីចម្បាំងដ៏ល្បីល្បាញមួយនៅក្នុងព្រហ្មញ្ញសាសនា និងគេស្គាល់ថាជាមហេសីរបស់ព្រះឥសូរ។ រឿងទេវកថាដែលគេស្គាល់ច្រើនរបស់ព្រះនាងទុគ៌ា គឺជាការប្រយុទ្ធគ្នាជាមួយអសុរដែលបង្ហាញទ្រង់មានព្រះហស្តច្រើន ហើយព្រះហស្តនីមួយៗកាន់អាវុធដែលទទួលបានមកពីទេពផ្សេងៗ។ រឿងរ៉ាវទេវកថាដែលសំខាន់ទាក់ទងនឹងទេពនេះ គឺមានឈ្មោះថា "ទុគ៌ាមហិង្សាសុរមាទ៌និ" ដែលជាទេវកថាបង្ហាញអំពីចម្បាំងប្រយុទ្ធគ្នារវាងព្រះនាងទុគ៌ា និងបិសាចក្របីមហិង្សាសរ ហើយនៅតណ្ហាគេនិយមឆ្លាក់បដិមាទាក់ទងសាច់រឿងនេះណាស់ (រូបលេខ១)។ មហិង្សាសុរ គឺជាពាក្យសំស្ក្រឹតដែលផ្សំឡើងដោយពាក្យ "មហិង្សា" មានន័យថា ក្របី និង "អសុរ" មានន័យថា បិសាច។[១] តាមគម្ពីរ Vâmana Purâna បានបង្ហាញថា ព្រះនាងទុគ៌ាកាន់កេតនភណ្ឌមួយចំនួនដូចជា ត្រីសូល៍បានមកពីព្រះឥសូរ, កង់ចក្រនិងខ្យង់ស័ង្ខបានមកពីព្រះវិស្ណុ, ផ្គាំនិងថូបានមកពីព្រះព្រហ្ម, វជ្រឬកាំរន្ទះបានមកពីព្រះឥន្ទ្រ, ខែលនិងដាវបានមកពីព្រះកាល, ព្រួញបានមកពីព្រះអគ្នី, ធ្នូបានមកពីព្រះវាយុ, បំពង់ពោរពេញដោយព្រួញនិងពូថៅបានមកពីព្រះសូរ្យ និងព្រះពិស្ណុការ។[២] ប៉ុន្តែ កេតនភណ្ឌទាំងនោះសិល្បករបង្ហាញជាទម្រង់ផ្សេងៗ អាស្រ័យទៅតាមព្រះហស្តរបស់ទ្រង់ដែលជួនកាលមាន ព្រះហស្ត ២, ៤, ៦, ៨, ១០ និង ១៨។[៣] ព្រះនាង ទុគ៌ាមានព្រះហស្ត១៨ ភ្នែកបី សក់ខ្មៅរលោង ហើយគេច្រើនតែឃើញរូបព្រះនាងទុគ៌ាក្នុងកាយវិការជ័យជម្នះលើការសម្លាប់ក្របីមហិង្សា រីឯរូបតំណាងព្រះនាងទុគ៌ាវិញ ច្រើនតែបង្ហាញសកម្មភាពមួយក្នុងទម្រង់ទឹកមុខស្ងប់ស្ងាត់ និងស្រទន់។[៤] នៅសម័យមុនអង្គរ ស.វ.ទី៦ ខ្មែរនិយមគោរពទេពអង្គនេះណាស់ ហើយបើតាមកស្តុតាងជារូបបដិមាគេបានរកឃើញយ៉ាងតិចក៏មាន ១៦ រូប ដែលមាននៅក្នុងទឹកដីខេត្តកំពង់ធំ កំពង់ចាម សៀមរាប តាកែវ កំពង់ស្ពឺ ព្រៃវែង។ល។[៥]

ដោយឡែក នៅតំបន់ប្រាសាទសំបូរព្រៃគុក ការបង្ហាញព្រះនាងទុគ៌ាជាបដិមាទោលមានតែមួយប៉ុណ្ណោះ គឺស្ថិតនៅតួប៉ម N9 នៃក្រុមប្រាសាទសំបូរឬក្រុមខាងជើង ដែលជាតួប៉មបែរមុខទៅទិសខាងត្បូងទល់មុខតួប៉មដែលតម្កល់រូបបដិមាព្រះហរិហរ (តួប៉ម N10)។ បដិមានេះកម្ពស់

[១] Cornelia & Buitenen 1978: 237.

[២] Wilkins 1982: 250.

[៣] Amazzone 2002: 4-5; Banerji 2006: 3-5.

[៤] Donald 1996: 5-7.

[៥] រឿន សុខលី ២០២០: ៣១-៤១។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

១៣០ ស.ម. ហើយបើគិតទាំងជើងទម្រមានកម្ពស់សរុប ១៦៥ស.ម. ឈររាងផ្ទៀងកាច់ចង្កេះ រូបរាងទន់ភ្លន់មិនកាចសាហាវ តែប្រកបដោយអំណាចទៅវិញ ដែលតំណាងឱ្យអំណាចព្រះឥសូរ និងព្រះវិស្ណុ ដែលមានសមត្ថភាពសម្លាប់បិសាចក្របី (រូបលេខ២)។[៦] ដើមឡើយ បដិមានេះបែកជាបីបំណែក ដែលពីរបំណែកខាងលើរកឃើញនៅកន្លែងតែមួយក្បែរតួប៉ម N1 ហើយប្រហែល៥០ឆ្នាំក្រោយមួយបំណែកខាងក្រោមរកឃើញនៅខាងមុខតួប៉ម N9។[៧] សព្វថ្ងៃ បដិមានេះគេតម្កល់ទុកនៅសារមន្ទីរជាតិភ្នំពេញ ហើយនៅសំបូរព្រៃគុកគេបានធ្វើរូបចម្លងមួយតម្កល់ក្នុងតួប៉ម N9។

ក្រៅអំពីការបង្ហាញព្រះនាងទុគ៌ាជាបដិមាទោល យើងឃើញចម្លាក់ព្រះនាងទុគ៌ាចំនួនពីរផ្ទាំងឆ្លាក់នៅលើជញ្ជាំងឥដ្ឋកំពែងខាងលិចនៃក្រុមប្រាសាទយាយព័ន្ធ។ ផ្ទាំងទីមួយ មានស្ថានភាពបាក់បែកច្រើន ដោយសារតែឥដ្ឋបានធ្លាក់មកក្រោមស្ទើរតែជិតអស់ទៅហើយ។ ប៉ុន្តែគេអាចនៅមើលឃើញផ្នែកខ្វះដូចជា ក្បាលក្របី ជើងគោ និងផ្នែកខ្វះនៃរូបទេពស្រីក្នុងកាយវិការចម្បាំង ដែលយើងអាចសន្និដ្ឋានបានថាជារូបព្រះនាងទុគ៌ានិងសត្វគោដែលជាយានជំនិះរបស់ទ្រង់កំពុងប្រយុទ្ធជាមួយបិសាចមហិង្សាសុរ ដែលគេបង្ហាញជារូបសត្វក្របីតែម្តង (រូបលេខ៣)។ ចម្លាក់មួយផ្ទាំងទៀតឆ្លាក់នៅក្បែរចម្លាក់ផ្ទាំងទីមួយដែរ នៅមានសភាពល្អប្រសើរច្រើន (រូបលេខ៤)។ ចម្លាក់នេះគេបង្ហាញទេពស្រីមួយអង្គនិងសត្វគោ កំពុងប្រយុទ្ធជាមួយបិសាច (អសុរទម្រង់ជាមនុស្ស)។ ព្រះនាងទុគ៌ាដែលបង្ហាញនេះ មានព្រះហស្តពីរកាន់អាវុធទាំងសងខាង ព្រះបាទម្ខាងជាន់លើខ្លួននិងម្ខាងទៀតកំពុងជល់ជង្គង់ទៅរកមុខបិសាច (អសុរ)។ អសុរដែលបង្ហាញនេះ ក៏ទំនងជារូបមហិង្សាសុរដដែល គ្រាន់តែសិល្បករបង្ហាញទម្រង់ជាមនុស្សដូចរូបនៅតណ្ហាដែលបង្ហាញខាងលើដែរ។

ជារួមមក បដិមានិងចម្លាក់ទាំងបីដែលបង្ហាញខាងលើគ្រាន់តែចង់បង្ហាញថា នៅសម័យមុនអង្គរនាស.វ.ទី៦-៧ ខ្មែរនិយមបង្ហាញចម្លាក់ព្រះនាងទុគ៌ាណាស់ ប៉ុន្តែមកដល់សម័យអង្គរហាក់ដូចជាលែងសូវនិយមវិញ។ រូបទាំងនេះបានបង្ហាញអំពីគំនិតរបស់សិល្បករខ្មែរនៅជំនាន់នោះ ក្នុងការចេះដឹងក្បួនច្បាប់ព្រហ្មញ្ញសាសនាបានទូលំទូលាយ ហើយយកមកអនុវត្តចេញជាចម្លាក់និងបដិមាទាំងនេះឡើង៕

---

[៦] Helen 2004: 40.

[៧] Khun Samen 2006: 67.

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

# បញ្ជីឯកសារយោង

**ឿន សុខលី**

២០២០, *ពិចារណាព្រះបដិមា និងចម្លាក់ព្រះនាងទុគ៌ានៅក្នុងសិល្បៈនិងប្រពៃណី*, ភ្នំពេញ

**Citrata, Banerji**

2006, *The hours of the goddess, memories of woman food and ritual in Benga*, New Delhi

**Dimmit, Cornelia & Buitenen, J.A.B**

1978, Classical Hindu Mythology, USA

**Donald J, Larocca**

1996, *The god of war sacred imagery and the decoration of arms and Armo Metropolition of art*, London

**Helen Ibbitson Jessup**

2004, "*Art & Architecture of Cambodia*", London

**Laura, Amazzone**

2002, *Goddes durga and sucred female power*, University Press of America

**Wilkins, W. J.**

1882, *Hindu mythology Vedic and Puranic*, London

KHMER CIVILIZATION



រូបលេខ១៖ បដិមាទុគ៌ារកឃើញនៅឥណ្ឌាខាងត្បូង
(សព្វថ្ងៃរក្សាទុកនៅសារមន្ទីរ V & A,  ទីក្រុងឡុងដ៍)

KHMER CIVILIZAT



រូបលេខ២៖ បដិមាទុគ៌ារកឃើញនៅសំបូរព្រៃគុក
តួប៉ម N9 (សព្វថ្ងៃរក្សាទុកនៅសារមន្ទីរជាតិភ្នំពេញ)



រូបលេខ២៣៖ ចម្លាក់ទុគ៌ាមហិង្សាសុរនៅជញ្ជាំងឥដ្ឋកំពែងខាងលិចប្រាសាទយាយព័ន្ធ



រូបលេខ២៤៖ ចម្លាក់ទុគ៌ាមហិង្សាសុរនៅជញ្ជាំងឥដ្ឋកំពែងខាងលិចប្រាសាទយាយព័ន្ធ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី